# ព្រឹត្តិបត្រព័ត៌មាន

## សាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន ពាមជីកង

លេខ០១ ខែមករា ឆ្នាំ២០២៤

ហ្វេសប៊ុកផេក៖ វិទ្យាល័យ ហ៊ុនសែន ពាមជីកងជំនាន់ថ្មី
លេខទូរសព្ទ៖ 096 7273 921/ 087 609 156
គេហទំព័រ www.pck.ngs.edu.kh
អ៊ីម៉ែល៖ ngspckhighschool@gmail.com

## មាតិកា


- ការគោរពទង់ជាតិ
- ការប្រើប្រាស់ឧបករណ៍ ICT សម្រាប់ជំនួយដល់អនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន
- កម្មវិធីសំណេះសំណាលជាមួយអាណាព្យាបាលសិស្សថ្នាក់ទី១០ថ្មី
- សកម្មភាពក្លឹប Technovation Girls ២០២៤
- ជំងឺដង្កូវព្រូនក្នុងពោះវៀន និងការផ្តល់ថ្នាំទម្លាក់សត្វល្អិតដល់សិស្ស
- ការទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសាលារៀនជំនាន់ថ្មី
- ពិធី “សំណេះសំណាលជាមួយសិស្សនិទ្ទេស A ក្នុងស្រុកកងមាស ខេត្តកំពង់ចាម”
- សកម្មភាពបង្រៀន និងរៀនម៉ោងជីវវិទ្យា
- ទស្សនកិច្ចរបស់ប្រតិភូចិន ដើម្បីពិនិត្យមើលការបង្រៀននិងរៀនមុខវិជ្ជាកុំព្យូទ័រ(ICT)
- ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូមកពីស្ថាប័ន Ligth over Ligth ប្រទេសម៉ាឡេស៊ី
- សកម្មភាពផ្សព្វផ្សាយច្បាប់ចរាចរណ៍ដល់សិស្សានុសិស្សវិ.ហ.ស ពាមជីកង
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានចុះណែនាំគ្រូបង្គោល និងសិស្សស្រីនៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង
- ប្រឡងប្រចាំខែមករា
- សកម្មភាពផ្សេងៗ


## ការគោរពទង់ជាតិ

សំពះ (កិ.) លើកដៃទាំងពីរផ្គុំម្រាមទាំង១០ឆ្ពោះត្រង់ទៅរកបុគ្គល, ទៅរកទីឬវត្ថុដែលគួរគោរព។

ការសំពះគឺជាការសម្តែងគារវកិច្ចចំពោះគ្នាទៅវិញទៅមករបស់មនុស្សទូទៅក្នុងសង្គម ជាពិសេសពុទ្ធសាសនិក ប៉ុន្តែបើនិយាយដល់ការសំពះនេះ ប្រជាពលរដ្ឋខ្មែរបានប្រកាន់យកធ្វើជាទំនៀមទំលាប់ប្រពៃណីរបស់ខ្លួនតាំងពីយូរលង់ណាស់មកហើយ ដោយចាស់ពីដើមបានយល់ថាការសំពះគឺជាការគោរព ដែលបង្ហាញឱ្យឃើញពីកាយវិការទន់ភ្លន់ សុភាពរាបសា មានសុជីវធម៌ និង ផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមក។

នាព្រឹកថ្ងៃព្រហស្បតិ៍ ៨រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៤ នេះ គណៈគ្រប់គ្រងនៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង បានធ្វើការណែនាំដល់ប្អូនៗសិស្សានុសិស្សអំពីសុជីវធម៌ ការចេះគោរពគ្នាតាមរយៈការលើកដៃសំពះគ្នាទៅវិញទៅមក ការសំពះគោរពចាស់ទុំ លោកគ្រូអ្នកគ្រូជាដើម។ ក្រៅពីការទទួលបានចំណេះដឹងហើយនោះ កុមារទាំងឡាយត្រូវមានសីលធម៌ សុជីវធម៌ គុណធម៌បន្ថែមទៀត ទើបល្អប្រសើរ។








# ការប្រើប្រាស់ឧបករណ៍ ICT សម្រាប់ជំនួយដល់អនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន




គ្រូបង្រៀនបច្ចេកវិទ្យាព័ត៌មាន នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង បានចូលរួមប្រជុំចែករំលែកពីការប្រើប្រាស់ឧបករណ៍ ICT សម្រាប់ជំនួយដល់ការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដែលផ្សារភ្ជាប់ជាមួយបច្ចេកវិទ្យាឌីជីថល ជូនដល់លោកគ្រូអ្នកគ្រូបង្រៀនផ្សេងទៀត ដើម្បីយកទៅចែករំលែកបន្តដល់សិស្សានុសិស្ស។








# កម្មវិធីសំណេះសំណាលជាមួយអាណាព្យាបាលសិស្សថ្នាក់ទី១០ថ្មី និងភ្ជាប់គ្រុប Telegram ជាមួយសាលា



កម្មវិធីសំណេះសំណាលជាមួយអាណាព្យាបាលសិស្សថ្នាក់ទី១០ថ្មី ដើម្បីស្វែងយល់ពីដំណើរការសាលារៀនជំនាន់ថ្មី នៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង និងភ្ជាប់គ្រុប Telegram ជាមួយសាលា ។

លទ្ធផលនៃកម្មវិធីសំណេះសំណាល គឺអាណាព្យាបាលសិស្សសោមនស្សរីករាយជាមួយនឹងសកម្មភាពរៀន និងបង្រៀន និងបន្តការគាំទ្រឱ្យដំណើរការសាលារៀនជំនាន់ថ្មីបន្តទៀត ។








# សកម្មភាពក្លឹប Technovation Girls ២០២៤ នៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង



កងមាស៖ នៅក្នុងសប្តាហ៍នេះដែរ ក្រុមយុវតីបាននឹងកំពុងកំណត់នូវបញ្ហាប្រឈមពិតប្រាកដដែលពួកគេបានជួបប្រទះនៅក្នុងសហគមន៍របស់ពួកគេ និងបានគូរនូវគំនូរព្រាងរូបរាងកម្មវិធីទូរសព្ទដៃ នៅលើក្រដាសដើម្បីបង្កើតជាកម្មវិធីទូរសព្ទដៃ។ កម្មវិធី Technovation Girls នេះគឺជាឱកាសដ៏ពិសេសមួយសម្រាប់ស្ត្រីវ័យក្មេងដើម្បីបង្ហាញពីគំនិតឆ្នៃប្រឌិត ចេះធ្វើការជាក្រុម មានការសហការគ្នាក្នុងក្រុម ចេះកំណត់គោលដៅពិតប្រាកដដើម្បីសម្រេចបានជោគជ័យ។









# ជំងឺដង្កូវព្រូនក្នុងពោះវៀន និងផ្តល់ថ្នាំទម្លាក់សត្វល្អិតដល់សិស្សានុសិស្ស នៃវិទ្យាល័យហ៊ុនសែនពាមជីកង



ពាមជីកង៖ នៅថ្ងៃសុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី៥ ខែមករា ឆ្នាំ២០២៤ អ្នកគ្រូពេទ្យ ទូច ភិរម្យ គ្រូពេទ្យប្រចាំការនៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង បានបង្រៀនសិស្សថ្នាក់ទី 8B2 និង9B2 ក្រោមប្រធានបទ “ជំងឺដង្កូវព្រូនក្នុងពោះវៀន និងផ្តល់ថ្នាំទម្លាក់សត្វល្អិតដល់សិស្សានុសិស្ស” ដែលការបង្រៀនប្រព្រឹត្តទៅចាប់ពីម៉ោង 7:15 ដល់ 9:45។









# ការទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសាលារៀនជំនាន់ថ្មី



នៅថ្ងៃសុក្រ ៩រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤ សាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន ពាមជីកង ទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសាលារៀនជំនាន់ថ្មី ។ ការទទួលបានវិញ្ញាបនបត្រនេះគឺ សាលាត្រូវអនុវត្តតាមគោលការណ៍នៃកម្មវិធីសាលារៀនជំនាន់ថ្មី និងលក្ខណៈវិនិច្ឆ័យទាំង២៤ ដែលមានចែងនៅគោលនយោបាយសាលារៀនជំនាន់ថ្មី និងគោលការណ៍ណែនាំប្រតិបត្តិសាលារៀនជំនាន់ថ្មី ។ ដោយសារវិញ្ញាបនបត្រនេះសិស្សទទួលបានការសិក្សាបែបថ្មីទំនើប មានសម្ភារៈរៀនគ្រប់គ្រាន់ រៀនពេញមួយថ្ងៃ មានបណ្ណាល័យស្អាត ទទួលបានទាំងចំណេះដឹង និងបំណិនសតវត្សទី២១ ។





# ពិធី “សំណេះសំណាលជាមួយសិស្សនិទ្ទេស A និងប្រគល់សម្ភារៈ សិក្សាដល់សិស្ស ចំណាត់ថ្នាក់លេខ១ ដល់លេខ៣ ថ្នាក់ទី២ ដល់ទី៦ ក្នុងស្រុកកងមាស ខេត្តកំពង់ចាម”

កំពង់ចាម៖ នាព្រឹកថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៤ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានក្រុមការងារថ្នាក់ជាតិ ចុះជួយស្រុកកងមាស បានអញ្ជើញចូលរួមជាអធិបតីក្នុង ពិធី សំណេះសំណាលជាមួយសិស្សនិទ្ទេស A នៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង និងវិទ្យាល័យ ហ៊ុន សែន កងតាណឹង ក្នុងស្រុកកងមាស ខេត្តកំពង់ចាម អមដំណើរដោយថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធក្រោមឱវាទក្រសួង ក្រុមការងារចុះជួយស្រុកកងមាសជាច្រើនរូបទៀត។

ក្នុងឱកាសនេះឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ លោក លោកស្រី នាយក នាយិកា លោកគ្រូ អ្នកគ្រូ និងបុគ្គលិកអប់រំទាំងអស់ ដែលបានខិតខំបំពេញ តួនាទីភារកិច្ចលះបង់ទាំងកម្លាំងកាយចិត្ត រហូតសម្រេចបានលទ្ធផលជាទីមោទនៈ និងសូមឱ្យបន្តស្មារតីសហការគ្នាដើម្បីលើកកម្ពស់វិស័យអប់រំ វិស័យអប់រំនៅកម្ពុជាឱ្យកាន់តែរីកចម្រើនជានិរន្តរ៍។

ជាមួយនេះដែរ ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានរំលឹកឡើងនូវអនុសាសន៍របស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ដែលបានកំណត់យកការអភិវឌ្ឍធនធានមនុស្ស ជាការងារអាទិភាពត្រូវវិនិយោគ ក្នុងដំណាក់កាលទី១ នៃសាស្ត្របញ្ចកោណ ដែលនេះជាភារកិច្ចចម្បងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយបានដាក់ចេញនូវ ស្តង់ដាសាលាគំរូ ចំនួន ៥ ដែល ផ្តោតលើ (ទី១) លទ្ធផលសិក្សារបស់សិស្ស (ទី២).ការបង្រៀននិងរៀន (ទី៣). ការចូលរួមរបស់សហគមន៍ (ទី៤). ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន (ទី៥). គណនេយ្យភាពរបស់សាលារៀន។ សាលារៀនទូទាំងប្រទេសនឹងត្រូវប្រឹងប្រែងប្រកួតប្រជែងគ្នាអនុវត្តឲ្យសម្រេចបានតាមស្តង់ដា ហើយសាលាដែលជាប់ស្តង់ដា នឹងទទួលបានពានរង្វាន់ជាសាលាគំរូពីសម្តេចមហាបវរធិបតី ដែលនឹងត្រូវប្រកាសនៅក្នុងសន្និបាតអប់រំថ្នាក់ជាតិនៅខែមីនា ឆ្នាំ២០២៤ខាងមុខនេះ។

ក្រោយពីការសំណេះសំណាល ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ក៏បាន ផ្តល់ជូនសម្ភារៈសិក្សា ដល់សិស្សជ័យលាភីដែលបានប្រឡងជាប់និទ្ទេស A ទាំង៧រូប សម័យប្រឡងឆ្នាំ២០២២-២០២៣ ក្នុងម្នាក់ទទួលបានកង់អាគុយចំនួនមួយគ្រឿង ដើម្បីជាការលើកទឹកចិត្តជំរុញឱ្យសិស្សានុសិស្សបន្តប្រឹងប្រែងរៀនសូត្របន្ថែមទៀត និងបានប្រគល់នូវសម្ភារសិក្សា មួយចំនួនដល់ស្រុក ទាំង១០ ក្នុងខេត្តកំពង់ចាម៕











# សកម្មភាពបង្រៀន និងរៀនម៉ោងជីវវិទ្យា





សកម្មភាពបង្រៀន និងរៀនម៉ោងជីវវិទ្យា

ថ្នាក់ទី 9B1 និង 9B2

ពិសោធ : ការសង្កេតមើលរូបផ្គុំក្នុងនៃស្លឹករុក្ខជាតិនិងអាមីដុងក្នុងដំឡូងបារាំងនិងទំពាំងបាយជូរ

បង្រៀនដោយអ្នកគ្រូ យឿន ពិសី











# ទស្សនកិច្ចរបស់ប្រតិភូចិនតាមរយៈនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យមើលការបង្រៀននិងរៀនមុខវិជ្ជាកុំព្យូទ័រ(ICT)



ថ្ងៃព្រហស្បតិ៍ ១កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង ជំនាន់ថ្មី បានទទួលការអញ្ជើញមកទស្សនកិច្ចរបស់ប្រតិភូចិនតាមរយៈនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យមើលការបង្រៀននិងរៀនមុខវិជ្ជាកុំព្យូទ័រ(ICT)









# ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូមកពីស្ថាប័ន Ligth over Ligthប្រទេសម៉ាឡេស៊ី អ្នកជំនាញខាងអប់រំSTEM



ថ្ងៃពុធ ៧កើត ខែបុស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង កម្មវិធីសាលារៀនជំនាន់ថ្មី តាមរយៈNGPRC បានទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូមកពីស្ថាប័ន Ligth over Ligth ប្រទេសម៉ាឡេស៊ី អ្នកជំនាញខាងអប់រំSTEM។ ទស្សនៈកិច្ចនេះគឺជាការចុះជួប និងពិភាក្សាការងារ ការទំនាក់ទំនង និងការងារការអប់រំSTEMដើម្បីធ្វើការសហការនិងគាំទ្រទៅលើផ្នែកនេះពី Ligth over Ligth មកដល់សាលារៀនជំនាន់ថ្មី។









# សកម្មភាពផ្សព្វផ្សាយច្បាប់ចរាចរណ៍ដល់សិស្សានុសិស្ស វិ. ហ.ស ពាមជីកង



ថ្ងៃព្រហស្បតិ៍ ៨ កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ លោកអធិការរង ស្រុកកងមាស បានចុះមកវិទ្យាល័យ ហ៊ុន សែន ពាមជីកង ដើម្បីមកផ្សព្វផ្សាយច្បាប់ចរាចរណ៍ដល់សិស្សានុសិស្ស និងផ្តល់ ជាដំបូន្មានដល់សិស្សានុសិស្សក្នុងការបើកបរពេលមកសាលាឬចេញពីសាលាដោយគោរពច្បាប់ចរាចរណ៍ឱ្យបានគ្រប់ៗគ្នា ដើម្បីជៀសផុតពីការផាកពិន័យផ្សេងៗ និងជៀសផុតពីគ្រោះថ្នាក់ផ្សេងៗ។









# នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានចុះណែនាំគ្រូបង្គោល និងសិស្សស្រី នៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង




នៅថ្ងៃសៅរ៍ ១០ កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានទទួលការមកដល់របស់មន្ត្រីនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានចុះណែនាំគ្រូបង្គោល និងសិស្សស្រីនៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង ពីសកម្មភាពក្រៅម៉ោងសិក្សា ការបង្កើតក្លឹប ICT Technovation Girls ដែលកុមារីសិក្សារៀងរាល់ចុងសប្តាហ៍។ កម្មវិធីនេះមានការបណ្តុះបណ្តាលរយៈពេល ៣ខែដើម្បីស្វែងយល់ពី សហគ្រិនភាព និងការការសរសេរកូដក្នុងការបង្កើតកម្មវិធីទូរសព្ទដៃ

ការចុះផ្តល់ជំនួយបច្ចេកទេសសកម្មភាពក្រៅម៉ោងសិក្សា ការបង្កើតក្លឹប ICT ដល់គ្រូបង្គោល និងសិស្សស្រីនៅបឋមសិក្សាថ្លុកជ្រៅ អនុវិទ្យាល័យអន្លងអក និងវិទ្យាល័យ ហ៊ុន សែន ពាមជីកង។








# ប្រឡងប្រចាំខែមករា



ពាមជីកង៖ នៅថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានរៀបចំការប្រឡងប្រចាំខែមករា ដល់សិស្សានុសិស្សគ្រប់កម្រិតថ្នាក់សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤ នៅតាមអគារនីមួយៗដោយមានភាពតឹងរឹងបំផុត ហើយនៅតាមបន្ទប់ប្រឡងមានគណៈកម្មការអនុរក្សចំនួនពីរនាក់ និងនៅតាមអគារប្រឡងនីមួយៗមានគណៈកម្មការត្រួតពិនិត្យអគារចំនួនមួយនាក់។ សិស្សានុសិស្សបានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការប្រឡងលើវិញ្ញាសានីមួយៗ និងពោរពេញដោយក្ដីសង្ឃឹម និងទន្ទឹងរង់ចាំមើលលទ្ធផលប្រឡងរបស់ខ្លួន។ ការប្រឡងប្រព្រឹត្តទៅយ៉ាងល្អ សិស្សានុសិស្សគ្រប់កម្រិតថ្នាក់បានគោរពនូវបញ្ញាត្តិក្នុងពេលប្រឡងបានយ៉ាងខ្ជាប់ខ្ជួន។









# សកម្មភាពផ្សេងៗ



សកម្មភាពសិស្សប្រើប្រាស់
Tablet ក្នុងបណ្ណាល័យ



សកម្មភាពសិស្សថ្នាក់ទី7C1
ស្រាវជ្រាវពីរុក្ខជាតិប៉ប្រក



ការធ្វើតេស្តស៊ីជម្រៅដើម្បីវាស់
វែងការគិតរបស់សិស្សថ្នាក់ទី៧



សកម្មភាពសិស្សថែរ
ដំណាំនៅក្នុងសួនបំណិនជីវិត



សកម្មភាពប្រជុំប្រចាំខែមករា



សកម្មភាពបំប៉នក្រុមប្រឹក្សាកុមារ
និងយុវជន